ធ៧-០១១-២៤១ ប្រ.ក

# ប្រកាស
# ស្តីពី
# អាជីវកម្មភតិសន្យាហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១**.-

ប្រកាសនេះ មានគោលបំណងបង្កើត លើកកម្ពស់ និងអភិវឌ្ឍវិស័យភតិសន្យាហិរញ្ញវត្ថុសំដៅផ្តល់គោលការណ៍ណែនាំសម្រាប់ប្រតិបត្តិករភតិសន្យាហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២**.-

គ្រឹះស្ថានធនាគារ អាចធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ដែលជាផ្នែកមួយនៃប្រតិបត្តិការរបស់ធនាគារដូចមានចែងក្នុងមាត្រា ២ ចំណុចទី១ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងមាត្រា៣៤ កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ។ គ្រឹះស្ថានធនាគាររួមមាន ធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ គ្រឹះស្ថានធនាគារត្រូវសុំការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា។ គ្រឹះស្ថានធនាគារត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសនេះ។

គ្រឹះស្ថានផ្សេងទៀតដែលមានបំណងផ្តល់ឬកំពុងផ្តល់ផលិតផលភតិសន្យាហិរញ្ញវត្ថុ ត្រូវសុំអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា។ លក្ខខណ្ឌសម្រាប់ស្នើសុំអាជ្ញាប័ណ្ណត្រូវបានកំណត់ដោយប្រកាសដោយឡែក។

**ប្រការ ៣**.-

ភតិសន្យាហិរញ្ញវត្ថុ សំដៅដល់ភតិសន្យាសម្រាប់រយៈពេលដំបូងមួយឆ្នាំ ឬច្រើនជាងដែលរយៈពេលនោះមិនអាចកែប្រែបាន ក្នុងនោះ៖

១. ភតិកៈបញ្ជាក់ច្បាស់លាស់នូវចលនវត្ថុ និងជ្រើសរើសអ្នកផ្គត់ផ្គង់ ដោយមិនផ្អែកសំខាន់លើជំនាញ និងការវិនិច្ឆ័យរបស់ភតិបតីឡើយ។

២. ភតិបតីទិញចលនវត្ថុតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុដើម្បីជួលឲ្យភតិកៈ។

ក៏ប៉ុន្តែ បើមានការជួលបន្តនូវចលនវត្ថុដែលបានជួលពីមុនពីភតិបតីដដែល ការជួលបន្តនោះអាចនៅតែជាភតិសន្យាហិរញ្ញវត្ថុដដែល។

ភតិសន្យាអាចជាភតិសន្យាហិរញ្ញវត្ថុ ដោយមិនគិតដល់៖

១. ការបង់ថ្លៃឈ្នួលភតិសន្យាត្រូវបានឬមិនត្រូវបានគណនាបញ្ចូលនូវការរំលស់ទាំងមូលឬការរំលស់មួយផ្នែកធំនៃតម្លៃចលនវត្ថុ ឬ

២. ភតិកៈមានឬពុំមានជម្រើសឬក្រោយមកទទួលយកជម្រើសថាទិញឬបន្តជួលចលនវត្ថុមួយរយៈពេលបន្ថែមទៀត។

**ប្រការ ៤**.-

ធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានបំណងធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុត្រូវ៖

១. មានស្ថានភាពហិរញ្ញវត្ថុ និងសកម្មភាពប្រតិបត្តិការរឹងមាំ អនុបាតសាធនភាព និងអនុបាតផ្សេងៗទៀត ស្របតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។

២. មានធនធានមនុស្ស និងសម្ភារៈគ្រប់គ្រាន់សម្រាប់ដំណើរការអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ។

៣. មានផែនការអាជីវកម្មច្បាស់លាស់ជាលាយលក្ខណ៍អក្សរសម្រាប់អាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាននោះ។

ផែនការនេះរួមបញ្ចូលនូវចំណុចសំខាន់ៗដូចខាងក្រោម៖

ក. គោលនយោបាយ និងនីតិវិធីសម្រាប់ប្រតិបត្តិការអាជីវកម្ម

ខ. សេចក្តីលម្អិតពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធរាយការណ៍សមស្រប។

សេចក្តីលម្អិតពីប្រព័ន្ធគ្រប់គ្រងហានិភ័យយ៉ាងហោចណាស់ត្រូវមាន៖

- ការវាយតម្លៃពីលំហូរសាច់ប្រាក់
- ប្រព័ន្ធវិភាគឥណទាន នីតិវិធីកំណត់កម្រិតឥណទានអតិថិជន និងនីតិវិធីកំណត់ប្រាក់កក់ និងកម្រៃផ្សេងៗ
- នីតិវិធីក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ ដូចជា ការទិញចលនវត្ថុ អ្នកផ្គត់ផ្គង់ ការគ្រប់គ្រងចលនវត្ថុដែលរឹបអូស ការតាមដាន និងត្រួតពិនិត្យចលនវត្ថុ ការវាយតម្លៃនៃតម្លៃសេសសល់របស់ចលនវត្ថុ និង
- ឯកទេសកម្ម និងការប្រមូលផ្តុំសមស្រប។

**ប្រការ ៥**.-

ចលនវត្ថុសម្រាប់ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុសំដៅដល់ទ្រព្យសម្បត្តិគ្រឿងចក្រ និងឧបករណ៍ទាំងអស់ លើកលែងតែ ដី និងអគារ។

លុះត្រាតែមានច្បាប់ ឬកិច្ចព្រមព្រៀងចែងផ្សេងពីនេះ ចលនវត្ថុដែលត្រូវបានភ្ជាប់ ឬត្រូវបានតម្លើងនៅក្នុងអគារ ឬលើដី ឬចលនវត្ថុដទៃទៀត ត្រូវរក្សាអត្តសញ្ញាណដាច់ដោយឡែករបស់ខ្លួន និងមិនក្លាយទៅជាចំណែកនៃដី ឬអគារ ឬចលនវត្ថុដទៃទៀតដែលត្រូវបានភ្ជាប់ជាមួយនោះទេ។

**ប្រការ ៦**.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧**.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៨**.-

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**